# ការចាត់ចែងចំពោះអ្នកដែលនឹងចូលមកប្រទេសជប៉ុន

ថ្ងៃទី26 ខែមិថុនា ឆ្នាំរេយវ៉ា 2 (ឆ្នាំ2020)
(ធ្វើបច្ចុប្បន្នភាពថ្ងៃទី 5 ខែកក្កដា ឆ្នាំ2021)
ទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន
Immigration Services Agency of Japan

## I អ្នកដែលគេបានផ្តល់ជូននូវលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ ឬអ្នកដែលកំពុងដាក់ពាក្យសុំលិខិតបញ្ជាក់លក្ខណៈសម្បត្តិស្នាក់នៅ

**(1) អ្នកដែលគេបានផ្តល់ជូននូវលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ**

តាមធម្មតា សុពលភាពគឺ 3ខែ ក៏ប៉ុន្តែមានការចាត់ទុកពិសេសដូចតទៅ៖

○ លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅណាដែលធ្វើឡើងក្នុងកម្លុងពេលពីថ្ងៃទី1 មករា 2020 ដល់ថ្ងៃទី31 កក្កដា 2021 ត្រូវបានចាត់ទុកថា មានសុពលភាពដល់ថ្ងៃទី31 មករា 2022។

○ លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅណាដែលធ្វើឡើងក្នុងកម្លុងពេលពីថ្ងៃទី1 សីហា 2021 ដល់ថ្ងៃទី31 មករា 2022 ត្រូវបានចាត់ទុកថា មានសុពលភាព 6 ខែ ដោយគិតពីថ្ងៃដែលបានធ្វើនោះ។

*លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ គឺដើម្បីបញ្ជាក់ភាពសមស្របនៃលក្ខខណ្ឌក្នុងការចូលប្រទេសជប៉ុននៅពេលដែលវាត្រូវបានចេញ។ ការពន្យារកម្លុងពេលសុពលភាពវែងពេក អាចធ្វើអោយអត្រានៃភាពខុសគ្នានៃកាលៈទេសៈនៅពេលចូលប្រទេសជប៉ុន និងពេលដែលលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅត្រូវបានចេញកើនឡើង។ ហេតុដូច្នេះហើយ សុពលភាពនៃលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅនឹងមិនត្រូវបានបន្តទៀតទេក្រោយពេលហួសកម្លុងពេលផុតសុពលភាពដូចខាងលើ។ ប៉ុន្តែចំពោះពាក្យសុំលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅដែលត្រូវបានដាក់ចាប់ពីថ្ងៃទី31 ខែកក្កដា ឆ្នាំ2022 និងមុនកាលបរិច្ឆេទកំណត់ដោយទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន ដែលគ្មានខ្លឹមសារប្រែប្រួលចាប់តាំងពីពេលដាក់ពាក្យលើកមុន នោះជាគោលការណ៍ លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅថ្មីបន្ទាន់មួយនឹងត្រូវបានចេញអោយក្រោយអ្នកស្នើសុំបានដាក់ជូននូវ (1)លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅដែលត្រូវបានចេញលើកមុន(ឯកសារដើម ឬថតចម្លង) និង (2)លិខិតបញ្ជាក់មូលហេតុដែលធ្វើឡើងដោយស្ថាប័នទទួល ។ល។ ព័ត៌មានលំអិត សូមមើល**កន្លែងនេះ**។

**(2) ចំពោះអ្នកដែលកំពុងដាក់ពាក្យសុំលិខិតបញ្ជាក់ការទទួលស្គាល់នូវលក្ខណៈសម្បត្តិស្នាក់នៅ**

ស្តីពីករណីដែលកំពុងដាក់ពាក្យសុំនេះ ហើយបើសិនជាមានការប្តូរពេលចាប់ផ្តើមធ្វើសកម្មភាព ជាគោលការណ៍ គេធ្វើការពិនិត្យសំណូមពាក្យដោយមើលតែលិខិតបញ្ជាក់មូលហេតុដែលធ្វើឡើងដោយស្ថាប័ន

## 2 អ្នកដែលបានចេញពីជប៉ុន ដោយមានការអនុញ្ញាតឱ្យចូលវិញ នៅពេលកំពុងដាក់ពាក្យសុំពាក់ព័ន្ធនឹងការស្នាក់នៅ

ក្នុងករណីដែលអ្នកដែលកំពុងចេញទៅប្រទេសក្រៅ ដោយមានការអនុញ្ញាតឱ្យចូលវិញ (រួមទាំងការចាត់ទុកថា មានការអនុញ្ញាតឱ្យចូលវិញ) បានដាក់ពាក្យសុំនូវការអនុញ្ញាតប្តូរលក្ខណៈសម្បត្តិស្នាក់នៅ ឬសុំការអនុញ្ញាតពន្យារលក្ខណៈសម្បត្តិស្នាក់នៅ ឬសុំការអនុញ្ញាតការស្នាក់នៅអចិន្ត្រៃយ៍ មុនពេលចេញពីជប៉ុន ហើយមិនអាចត្រឡប់មកវិញបានដោយសារឥទ្ធិពលនៃជម្ងឺឆ្លងកូវីដ១៩, គេទទួលស្គាល់នូវការទទួលជំនួសនូវប័ណ្ណស្នាក់នៅ ពាក់ព័ន្ធនឹងការអនុញ្ញាតនៃការដាក់ពាក្យសុំនេះ ដោយសាច់ញាតិនៅជប៉ុន ឬដោយបុគ្គលិកនៃស្ថាប័នទទួល ជាអាទិ៍ ហើយអ្នកដែលកំពុងចេញពីជប៉ុន អាចដាក់ពាក្យសុំចូលតាមរយៈការអនុញ្ញាតឱ្យចូលវិញ។

## 3 អ្នកដែលកម្លុងពេលអាចចូលវិញបានកន្លងផុតទៅហើយ នៅពេលកំពុងចេញពីជប៉ុនដោយមានការអនុញ្ញាតឱ្យចូលវិញ ជាអាទិ៍

(1) អ្នកដែលមិនមែនជាមុខសញ្ញានៃការផ្តល់លិខិតទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ (“អ្នកស្នាក់នៅអចិន្ត្រៃយ៍” ជាអាទិ៍)

សូមទៅដាក់ពាក្យសុំទិដ្ឋាការនៅស្ថានទូតឬកុងស៊ុលជប៉ុននៅប្រទេសដែលស្នាក់នៅ។

※ស្តីពីអ្នកស្នាក់នៅអចិន្ត្រៃយ៍ ព័ត៌មានលំអិត សូមមើល**កន្លែងនេះ**។

※ស្តីពី “អ្នកស្នាក់នៅជាប់លាប់(ក្រៅពីការប្រកាសជាសាធារណៈ)” និង “សកម្មភាពពិសេស (ក្រៅពីការប្រកាសជាសាធារណៈ)” ព័ត៌មានលំអិត សូមមើល**កន្លែងនេះ**។

(2) អ្នកដែលជាមុខសញ្ញានៃការចេញលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ (និស្សិត, កម្មសិក្សាការីហ្វឹកហ្វឺនជំនាញ, វិទ្យាសាស្ត្រ-ចំណេះដឹងអំពីមនុស្សសាស្ត្រ-ការងារអន្តរជាតិ ជាអាទិ៍)

អ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅជប៉ុនរយៈពេលវែង (និស្សិត ឬកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ជាអាទិ៍) ហើយមិនអាចត្រឡប់មកវិញដោយសារឥទ្ធិពលនៃជម្ងឺឆ្លងកូវីដ១៩ ជាគោលការណ៍ គេធ្វើការពិនិត្យតែសំណូមពាក្យ និង លិខិតបញ្ជាក់មូលហេតុដែលធ្វើឡើងដោយស្ថាប័នទទួលប៉ុណ្ណោះ។ ※ព័ត៌មានលំអិត សូមមើល**កន្លែងនេះ**។

(3) អ្នកដែលស្នាក់នៅដោយលក្ខណៈសម្បត្តិ “ឯកទេសកម្រិតខ្ពស់ លេខ 2”

សូមដាក់ពាក្យសុំលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅទៅតាមសកម្មភាពដែលបានធ្វើពីមុន ក្នុងនាមជា “ឯកទេសកម្រិតខ្ពស់**លេខ 1**” យោងតាមចំណុច (2) ។ (គេនឹងចេញទិដ្ឋាការដោយមានលក្ខណៈសម្បត្តិស្នាក់នៅ “ឯកទេសកម្រិតខ្ពស់លេខ 1” តែពេលមកដល់ជប៉ុន អាចធ្វើនីតិវិធីចូលប្រទេសជប៉ុនជាថ្មីដោយមានលក្ខណៈសម្បត្តិ “ឯកទេសកម្រិតខ្ពស់លេខ 2” នៅអាកាសយានដ្ឋានជប៉ុនពេលចូលវិញបាន។)